01030124

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

លេខ/N°: D185/1/1/2

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ០៨)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន** **ប្រធាន**
**ចៅក្រម** Rowan DOWNING
**ចៅក្រម ន័យ ថុល**
**ចៅក្រម** Chang-Ho CHUNG
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 11 / 2014
ម៉ោង (Time/Heure): 15:25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ: (សំណៅកោសលុប)**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធពាក្យសុំមោឃភាព**

**សហព្រះរាជអាជ្ញា:**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី:**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Annie DELAHAIE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
François GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Emmanuel JACOMY
Beini YE

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើញត្តិរបស់ [redacted] ស្នើសុំមោឃភាពកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង" ដែលដាក់ដោយមេធាវីការពារ [redacted] ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៤ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. **ប្រវត្តិនីតិវិធី**

1. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ទៅសហចៅក្រមស៊ើបអង្កេត ដោយចោទប្រកាន់ពីបទឧក្រិដ្ឋដែល [redacted] អាចជាអ្នកទទួលខុសត្រូវ[2]។ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ និងនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមចំនួនពីរ ដោយចោទប្រកាន់ពីបទឧក្រិដ្ឋដទៃទៀតដែល [redacted] អាចជាអ្នកទទួលខុសត្រូវផងដែរ[3]។

2. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០ និងនៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ អង្គភាពគាំពារការការពារក្តី បានស្នើសុំឲ្យជនសង្ស័យក្នុងសំណុំរឿង ០០៣ និង ០០៤ អាចចូលពិនិត្យមើលសំណុំរឿង និងទទួលបានសិទ្ធិក្នុងនីតិវិធីដទៃទៀត ដូចមានចែងក្នុងវិធានផ្ទៃក្នុង វិធាន ៥៥(៨), ៥៥(១០) និង ២១[4]។ នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត ("សហចៅក្រម

---

[1] បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើញត្តិរបស់ [redacted] ស្នើសុំមោឃភាពកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៣, ឯកសារ D185/1/1/1។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញា, ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ឯកសារ D1។ ការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩,ឯកសារ D1/1។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់របស់សហព្រះរាជអាជ្ញា ទាក់ទងទីតាំងឧក្រិដ្ឋកម្ម និងការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោម, ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ D65 និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ សហព្រះរាជអាជ្ញា ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ, ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D191។

[4] លិខិតរបស់ប្រធានអង្គភាពគាំពារការការពារក្តី ផ្ញើជូនសហចៅក្រមស៊ើបអង្កេតដែលមានចំណងជើងថា "លិខិតរបស់អង្គភាពគាំពារការការពារក្តី ស្តីពីសិទ្ធិការពារក្តី នៅក្នុងសំណុំរឿង ០០៣ និង ០០៤", ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០, ឯកសារ D4.1.29។ លិខិតរំលឹកលើលិខិតរបស់អង្គភាពគាំពារការការពារក្តី ស្តីពីសិទ្ធិការពារក្តី នៅក្នុងសំណុំរឿង ០០៣ និង ០០៤, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ A1/1។

01030126



ស៊ើបអង្កេត" យូ ប៊ុនឡេង និង Blunk) បានបដិសេធមិនឱ្យចូលពិនិត្យមើលសំណុំរឿង ដោយសារតែពួកគាត់មិនចាត់ទុកថាជនសង្ស័យ រួមទាំង [redacted] ផង គឺជាភាគីនៃកិច្ចដំណើរការនីតិវិធីនោះឡើយ ដោយសារតែពួកគេមិនទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការ តាមនីតិវិធីដែលមានចែងក្នុងវិធាន ៥៧ នៃវិធានផ្ទៃក្នុង ហើយផលប្រយោជន៍របស់ពួកគេក៏មិនត្រូវ "ទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ" ដោយសារតែកិច្ចស៊ើបសួរ រហូតដល់កម្រិតមួយដែលតម្រូវឱ្យធ្វើដូច្នេះនោះឡើយ[5]។

3. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនៅពេលនោះ ("សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង" KASPER-ANSERMET) បានចេញឯកសារ នៃការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ ដោយជូនដំណឹងដល់ [redacted] ថា "លោកត្រូវបានជាប់ឈ្មោះថាជាជនសង្ស័យម្នាក់នៅក្នុងកិច្ចស៊ើបសួរកំពុងបន្តដំណើរការ [ហើយ] មានសិទ្ធិមានលទ្ធភាពទទួលបានឯកសារសំណុំរឿង" ហើយឯកសារនេះត្រូវបានអានផ្ទាល់មាត់ឱ្យ [redacted] ស្តាប់ នៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២[6]។

4. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ [redacted] បានដាក់ញត្តិបន្ទាន់មួយស្នើសុំចូលពិនិត្យមើលសំណុំរឿង ហើយបានស្នើសុំដល់សហចៅក្រមស៊ើបអង្កេតឱ្យបង្គាប់ដល់ការិយាល័យរដ្ឋបាល ឱ្យផ្តល់សិទ្ធិចូលពិនិត្យមើលសំណុំរឿងដល់ [redacted] ដោយរំឭកថា [redacted] "ដែលជាជនត្រូវចោទ ត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ជូនដំណឹងថា គាត់មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង"[7]។ នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ [redacted] បានស្នើសុំផងដែរដល់សហចៅក្រមស៊ើបអង្កេត ឱ្យអនុញ្ញាតឱ្យគាត់អាចចូលរួមក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ ជាពិសេសស្នើសុំសួរ

---

[5] លិខិតរបស់សហចៅក្រមស៊ើបអង្កេត ផ្ញើជូនប្រធានអង្គភាពគាំពារការការពារក្តី ដែលមានចំណងជើងថា "ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសិទ្ធិការពារក្តី នៅក្នុងសំណុំរឿង ០០៣ និង ០០៤", ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០,ឯកសារ D4.1.31។

[6] ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន២១(១)(ឃ)], ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D110។ ការបញ្ជាក់អំពីការប្រគល់ឯកសារ, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D110.1។

[7] សំណើជាបន្ទាន់សុំដីកាបង្គាប់ឱ្យការិយាល័យរដ្ឋបាលអនុញ្ញាតឱ្យក្រុមមេធាវីការពារក្តី ពិនិត្យមើលសំណុំរឿង, ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២,ឯកសារ D121/2/1.1.1។

ដេញដោលទល់មុខជាមួយសាក្សីទាំងអស់ដែលសហចៅក្រមស៊ើបអង្កេតបានធ្វើការស្តាប់ចម្លើយ ហើយនឹងសុំអនុញ្ញាតដាក់សំណួរទៅកាន់សាក្សីទាំងនោះ[8]។

5. នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("សហចៅក្រមស៊ើបអង្កេតអន្តរជាតិ" HARMON) បានចេញ*សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី* [redacted] *សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ("សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើ ការចូលពិនិត្យ និងការចូលរួម") ដែលប្រកាសថា [redacted] ដោយសារតែមិនមានបទចោទប្រកាន់រូបគាត់ ទើបគាត់មិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធី ដូច្នេះគាត់មិនមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការឡើយ[9]។

6. នៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៣ មេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើ ការចូលពិនិត្យ និងការចូលរួម ដោយស្នើដល់អង្គបុរេជំនុំជម្រះ ឱ្យច្រានចោលសេចក្តីសម្រេចនេះ និងបង្គាប់ថា មេធាវីរបស់ [redacted] ដែលត្រូវបានទទួលស្គាល់ ត្រូវទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿង និងអនុញ្ញាតឱ្យចូលរួមក្នុងការស៊ើបអង្កេត[10]។

7. នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានចេញ*ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់* [redacted] *ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណើសុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត* ("*ការពិចារណារបស់ អ.ប.ជ*") ដែលក្នុងនោះបានប្រកាសថា ចៅក្រមជាតិ និងចៅក្រមអន្តរជាតិ មិនអាចស្វែងរកសំឡេងភាគច្រើន

---

[8] លិខិតរបស់មេធាវីការពារក្តី ជូនសហចៅក្រមស៊ើបអង្កេត អំពីការចូលរួមក្នុងដំណើរការស៊ើបអង្កេតសំណុំរឿង ០០៤, ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ D121/3។

[9] សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត, ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣, ឯកសារ D121/4។

[10] បណ្តឹងឧទ្ធរណ៍ប្រឆាំងសេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត, ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៣, ឯកសារ D121/4/1។

01030128



លើសលប់ដើម្បីចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះឡើយ[11]។ ចៅក្រមបីរូបនៃអង្គបុរេជំនុំជម្រះ "យល់ស្របជាមួយការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត" ដែលថា "[redacted] គឺជាជនសង្ស័យ" ទើបគាត់មិនមែនជាភាគី ដូច្នេះសម្រេចថាបណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេ"[12]។ ផ្ទុយទៅវិញចៅក្រមពីររូបរបស់អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើសុំចូលពិនិត្យសំណុំរឿង និងការចូលរួមកិច្ចស៊ើបអង្កេត ។ គួរត្រូវបានបដិសេធដោយសារតែ "[redacted] ស្ថិតនៅក្រោមកម្មវត្ថុនៃការចោទប្រកាន់ចាប់តាំងពីពេលដែលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានដាក់កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩" ដូច្នេះត្រូវផ្តល់សិទ្ធិដល់គាត់ ឲ្យដូចនឹងអ្វីដែលបានផ្តល់ដល់ជនត្រូវចោទ ដូចមានចែងក្នុងវិធានផ្ទៃក្នុង[13]។ សេចក្តីសម្រេចបន្ទាប់ពីមានការយល់ឃើញផ្សេងគ្នារបស់ចៅក្រមអង្គបុរេជំនុំជម្រះ ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង គឺសេចក្តីសម្រេចដែលរងការជំទាស់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើ ការចូលពិនិត្យ និងការចូលរួម ដោយផ្អែកលើមូលដ្ឋានថាគាត់មិនមែនជាភាគី ត្រូវបានតម្កល់ទុកជាបានការ[14]។

8. នៅថ្ងៃដដែល គឺថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ ញត្តិរបស់ [redacted] ស្នើសុំមោឃភាពកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង ("ញត្តិសុំមោឃភាព")[15]។

9. នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ មេធាវីការពារក្តី បានដាក់ញត្តិមួយទៀតស្នើសុំការពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើ ការចូលពិនិត្យ និងការ

[11] ការពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណើសុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត, ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤, ឯកសារ D121/4/1/4។

[12] ដូចជើងទំព័រខាងលើ មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ចៅក្រម ន័យ ធុល, ចៅក្រម ហួត វុទ្ធី, កថាខណ្ឌ ១៥ ដល់ ១៦។

[13] ដូចជើងទំព័រខាងលើ មតិយោបល់របស់ចៅក្រម Chang-ho CHUNG និងចៅក្រម Rowan DOWNING, កថាខណ្ឌ ២៤។

[14] ដូចជើងទំព័រខាងលើ។

[15] ញត្តិរបស់ [redacted] ស្នើសុំមោឃភាពកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤, ឯកសារD185។

ចូលរួម (*"ញត្តិស្នើសុំពិចារណាឡើងវិញ"*)[16] ដោយលើកជាទឡ្ហីករណ៍ថា "ការយល់ឃើញរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះនៅក្នុង ការពិចារណារបស់អង្គបុរេជំនុំជម្រះ អាចចាត់ទុកថាជាការផ្លាស់ប្តូរដ៏សំខាន់មួយនៃកាលៈទេសៈ"[17] ហើយថា "សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ [ការចូលពិនិត្យ និងការចូលរួម] មានកំហុសឆ្គងក្នុងការសន្មតថា [redacted] គឺជាជនសង្ស័យ ដោយផ្តោតយ៉ាងតឹងរ៉ឹងលើលក្ខខណ្ឌតម្រូវផ្លូវការសម្រាប់ការចោទប្រកាន់នៅ អ.វ.ត.ក"[18]។

10. នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីសម្រេចចំនួនពីរ៖ ១) ដីកាសម្រេចលើសំណើពិចារណាឡើងវិញ លើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើររបស់ក្រុមមេធាវីការពារក្តី [redacted] សុំពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត (*"ដីកាសម្រេចលើការពិចារណាឡើងវិញ"*)[19] និង ២) ដីកាសម្រេចលើញត្តិរបស់[redacted] ស្នើសុំមោឃភាពកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង (*"ដីកាសម្រេចដែលរងការជំទាស់"*)[20]។ ជាបឋម នៅក្នុងដីកាសម្រេចលើការពិចារណាឡើងវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ រកមិនឃើញការផ្លាស់ប្តូរកាលៈទេសៈ ដែលតម្រូវឲ្យមានការពិចារណាឡើងវិញលើសេចក្តីសម្រេចលើការចូលពិនិត្យ និងការចូលរួម ហើយនៅតែ*បន្តអះអាង*ថា [redacted] គឺជាជនសង្ស័យម្នាក់ មិនមែនជាជនត្រូវចោទនោះទេ ហើយសម្រេចថា[redacted] មិនមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ឬចូលរួមក្នុងកិច្ចស៊ើបអង្កេតឡើយ[21]។

---

[16] ញត្តិរបស់ [redacted] ស្នើសុំឱ្យពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើការស្នើសុំចូលពិនិត្យមើលសំណុំរឿង និងការចូលរួមក្នុងកិច្ចស៊ើបសួរ, ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤, ឯកសារD121/4/4។

[17] ដូចជើងទំព័រខាងលើ, កថាខណ្ឌ ២៣។

[18] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៨។

[19] ដីការសម្រេចលើសំណើពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ក្រុមមេធាវីការពារក្តី [redacted] សុំពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត, ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D121/4/6។

[20] ដីកាសម្រេចលើញត្តិរបស់ [redacted] ស្នើសុំមោឃភាពកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤, ឯកសារD185/1។

[21] ដីកាសម្រេចលើការពិចារណាឡើងវិញ, កថាខណ្ឌ ២៤ ដល់២៦។

11. ទីពីរ នៅក្នុងដីកាសម្រេចដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ញត្តិស្នើសុំមោឃភាពមិនអាចទទួលយកបាន ព្រោះ [redacted] មិនមានសិទ្ធិដាក់ញត្តិបែបនេះឡើយ ដោយសារតែគាត់មិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី ហើយវិធានផ្ទៃក្នុង ២១(១) ក៏មិនអនុញ្ញាតឱ្យ [redacted] មានមធ្យោបាយផ្សេងដើម្បីដាក់ញត្តិដែរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏យល់ឃើញបន្ថែមថា "មិនទាន់ដល់ពេលដែលត្រូវការកំណត់យុត្តាធិការ[បុគ្គល] នៅដំណាក់កាលនៃការស៊ើបអង្កេតឡើយ"។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានសន្និដ្ឋានផងដែរថា សំណើរបស់ក្រុមមេធាវីការពារក្តី មិនអាចទទួលយក ពីព្រោះថាក្រុមមេធាវីការពារក្តី មិនបានបង្ហាញថាកិច្ចស៊ើបសួរជាក់លាក់ណាមួយដែលនឹងត្រូវធ្វើមោឃភាព ហើយសំណើក៏មិនមានចែងតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុងដែរ ដោយសារតែសិទ្ធិអំណាចក្នុងការមោឃភាពកិច្ចស៊ើបអង្កេតមិនស្ថិតនៅលើសហចៅក្រមស៊ើបអង្កេតនោះទេ តែជាសិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ"[22]។

12. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍ស្នើសុំដល់អង្គបុរេជំនុំជម្រះឱ្យសម្រេចថាបណ្តឹងឧទ្ធរណ៍អាចទទួលយកបាន ហើយច្រានចោលដីកាសម្រេចដែលរងការជំទាស់ ហើយពិចារណាថាខ្លួនបានទទួលញត្តិសុំមោឃភាព និងធ្វើមោឃភាពកិច្ចស៊ើបអង្កេតតាមការស្នើសុំ[23]។

## II. បញ្ហាបឋមនៃសិទ្ធិប្តឹង

13. បញ្ហានៃសិទ្ធិប្តឹង ឬថាតើញត្តិត្រូវបានលើកឡើងដោយត្រឹមត្រូវឬអត់នោះ "ត្រូវបានពិចារណារួចហើយដោយអង្គបុរេជំនុំជម្រះ ហើយគឺជាផ្នែកនៃយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះអន្តរជាតិដទៃទៀតនៅក្នុងការពិចារណារបស់ពួកគេទៅលើភាពអាចទទួលយកបាននៃញត្តិ មុនពេលចូលទៅដល់អង្គសេចក្តី"[24]។

---

[22] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៣។

[23] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧២។

[24] សេចក្តីសម្រេចលើញត្តិស្នើសុំការពិចារណាឡើងវិញ លើសេចក្តីសម្រេចចំពោះសំណើរបស់អង្គភាពគាំពារការការពារក្តី សុំផ្អាក កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងស្នើសុំវិធានការទាក់ទងការធ្វើជាតំណាងប្រកបដោយប្រសិទ្ធភាព *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់* [redacted] *ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធពាក្យសុំមោឃភាព*

សម្រាប់ជនសង្ស័យក្នុងសំណុំរឿង ០០៤, ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១៤, Doc. No. 5 (បណ្តឹងឧទ្ធរណ៍លេខ PTC 01), កថាខណ្ឌ ៤ និយាយយោងដល់៖ សំណុំរឿងលេខ 002/07-12-2009-អ.វ.ត.ក/អ.ប.ជ (05), សេចក្តីសម្រេចលើសំណើរបស់ អៀង សារី និងអៀង ធីរិទ្ធ តាមវិធាន ៣៤ សុំប្តឹងជំទាស់ ចៅក្រម Marcel Lemonde, Doc. No. 8., ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ២០។ សំណុំរឿងលេខ 002/19-09-2007-អ.វ.ត.ក/ក.ស.ច.ស (PTC 47 & 48), សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ឯកសារ D250/3/2/1/5, ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ កថាខណ្ឌ ១៧។ សំណុំរឿងលេខ 002/19-09-2007-អ.វ.ត.ក/ក.ស.ច.ស (PTC 43), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំង ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំដាក់ ឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩, ឯកសារ D3/3/2/2, ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០, កថាខណ្ឌ ១៣ ដល់១៤។ សំណុំរឿងលេខ 002/19-09-2007-អ.វ.ត.ក/ក.ស.ច.ស(PTC 57), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន, ឯកសារ D193/5/5, ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១០, កថាខណ្ឌ ១៥ ដល់១៦។ ពាក្យសុំលេខ 002/08-07-2009-អ.វ.ត.ក/អ.ប.ជ, សេចក្តីសម្រេចលើពាក្យសុំរបស់ជនត្រូវចោទ ប្តឹងជំទាស់លោក Stephen Heder និងលោក David Boyle, Doc. No. 3, ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៩, កថាខណ្ឌ 20, 22 *និងចំពោះ៖* តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន, សាលដីកាលើបណ្តឹងសាទុក្ខ ចំពោះដីកាសម្រេចរបស់ចៅក្រមអង្គបុរេជំនុំជម្រះ ពាក់ព័ន្ធយុត្តាធិការ និងតួនាទី, CH/AC/2010/02, អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០, កថាខណ្ឌ ៥៥។ រដ្ឋអាជ្ញា តទល់និង Tadić, IT-94-1, នៅក្នុងសាលដីកា Dragan Opaćić អំពីការស្នើសុំការអនុញ្ញាតប្តឹងសាទុក្ខ, អង្គជំនុំជម្រះតុលាការកំពូល, ទំព័រ ២ (ដោយកត់សម្គាល់ថា ស្ថិតក្នុងកម្រិតដែលសេចក្តីសម្រេចលើបញ្ហាដែលផ្អែកលើតួនាទី ហាក់ដូចជា "មានលក្ខណៈផ្លូវច្បាប់ហួស ទើបសេចក្តីសម្រេចដទៃផ្សេងទៀត នឹងនាំទៅដល់ការប្តឹងសាទុក្ខដោយតុលាការ ចំពោះអ្នកមែនមែនជាភាគី... ដែលអាចគិតគូរដល់ការដាក់ពាក្យបណ្តឹង... តែនេះមិនអាចមាននោះឡើយ)"។ រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកដទៃទៀត, SCSL-04-16-AR77, សាលដីកាលើបណ្តឹងសាទុក្ខរួមគ្នារបស់មេធាវីការពារក្តី ប្រឆាំងសេចក្តីសម្រេចលើ របាយការណ៍របស់មេធាវីឯករាជ្យ ដោយអនុលោមតាមវិធាន 77(C)(iii) and 77(D), អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥។ ដីកាសម្រេចទាក់ទងយុត្តាធិការរបស់តុលាការ ក្នុងការសម្រេចលើពាក្យស្នើសុំរបស់លោក El Sayed ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១០ និងថាតើ លោក El Sayed មានតួនាទីដែរឬទេនៅចំពោះមុខតុលាការ,តុលាការ STL, ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០, CH/PTJ/2010/005។ រដ្ឋអាជ្ញា តទល់នឹង Kordicនិងអ្នកដទៃទៀត, IT-95-14/2, "សេចក្តីសម្រេចបញ្ជាក់ពីសំអាងហេតុ ចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៩៩ បដិសេធញត្តិរបស់មេធាវីការពារក្តីសុំលប់ចោលភស្តុតាង", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៩។ រដ្ឋអាជ្ញា តទល់នឹង Bobetko, IT-02-62-AR54bis & IT-02-62-AR108bis, "សេចក្តីសម្រេចលើការជំទាស់របស់ប្រទេសក្រូអាត ចំពោះសេចក្តីសម្រេច និងដីការបស់ចៅក្រមពេញសិទ្ធិ", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២, កថាខណ្ឌ ១០ ដល់១២។ ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ, ICC-01/04, "សេចក្តីសម្រេចលើសំណើសុំការអនុញ្ញាតប្តឹងឧទ្ធរណ៍ លើសេចក្តីសម្រេចស្តីពី សំណើសុំរបស់ OPCV", អង្គបុរេជំនុំជម្រះ ១, ចុះថ្ងៃទី ១៨ ខែ

14. នៅក្នុងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន មេធាវីការពារក្តីអះអាងថា ដីកាសម្រេចដែលរងការជំទាស់ បានសម្រេចដោយខុសឆ្គងថា [redacted] មិនមានឋានៈតួនាទីក្នុងការដាក់ញត្តិស្នើសុំមោឃភាពនោះទេ[25]។ ដើម្បីរក្សាការអះអាងបែបនេះ មេធាវីការពារក្តីបានអះអាងឡើងវិញនូវទឡ្ហីករណ៍ដដែល ដូចនឹងអ្វីដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ប្រឆាំងសេចក្តីសម្រេចលើការចូលពិនិត្យ និងការចូលរួម[26] ដែលអង្គបុរេជំនុំជម្រះមិនអាចស្វែងរកសំឡេងភាគច្រើនលើសលប់ដែលចាំបាច់សម្រាប់ការចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ គឺថាសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវតម្កល់ទុកជាបានការ។ បន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានច្រានចោលសំណើសុំឲ្យពិចារណាឡើងវិញ លើសេចក្តីសម្រេចលើការចូលពិនិត្យ និងការចូលរួម។ ស្ថិតក្នុងកាលៈទេសៈនេះ និងដោយពិចារណាថាចៅក្រមទាំងប្រាំរូបនៃអង្គបុរេជំនុំជម្រះ នឹងមានមតិយោបល់ដូចមតិយោបល់លើកមុនរបស់ខ្លួនចំពោះបញ្ហានៃឋានៈ ដោយសារតែបញ្ហាមូលដ្ឋានសម្រាប់ការយល់ឃើញខុសគ្នានេះ នឹងនៅតែបន្តដដែល ដូច្នេះបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននឹងនាំទៅដល់លទ្ធផលដដែល សម្រាប់ម្ចាស់បណ្តឹងឧទ្ធរណ៍ គឺដីកាសម្រេចដែលរងការជំទាស់ នឹងត្រូវតម្កល់ទុកជាបានការ ដោយអនុវត្តតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង។ ដូចដែលបានកត់សម្គាល់រួចហើយនៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ PTC07 ស្ថានភាពបែបនេះ

---

មករា ឆ្នាំ ២០០៨, កថាខណ្ឌចុងក្រោយ។ រដ្ឋអាជ្ញា តទល់នឹង Ndayambaje និងអ្នកដទៃទៀត, ICTR-98-42-AR73, "សាលដីកាលើបណ្តឹងសាទុក្ខរបស់ Joseph Kanyabashi ប្រឆាំងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ២ នៅថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០៧ ទាក់ទងការច្រានចោលញត្តិស្នើសុំផ្លាស់ប្តូរបញ្ជីសាក្សីរបស់គាត់", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៧, កថាខណ្ឌ ១៤ ហើយអនុវត្តឡើងវិញនៅក្នុង រដ្ឋអាជ្ញា តទល់នឹង Nyiramasuhuko និងអ្នកដទៃទៀត, សំណុំរឿងលេខ ICTR-97-21-T, និងរដ្ឋអាជ្ញា តទល់នឹង Kanyabashi, សំណុំរឿងលេខ ICTR-96-15-T, សំណុំរឿងរួមគ្នាលេខ ICTR-98-42-T, "សេចក្តីសម្រេចលើញត្តិរបស់ Nyiramasuhuko សុំការបញ្ជាក់ពីបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧ និងញត្តិរបស់ Ntahobali សុំការបញ្ជាក់ពីបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនៅថ្ងៃទី ០៥ និង ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧", អង្គជំនុំជម្រះសាលាដំបូង ២, ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៧ កថាខណ្ឌ ៤៤។

[25] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥០ ដល់ ៥៨។

[26] សូមមើលជាឧទាហរណ៍ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណើរបស់ក្រុមការពារក្តី សុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត, ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៣, ឯកសារD121/4/1/1 កថាខណ្ឌ ១៧ ដល់ ២៤ និង ៦១ ដល់៨០។

បង្ហាញថាបណ្តឹងឧទ្ធរណ៍មិនមានប្រយោជន៍ ហើយបង្កើតជាលទ្ធភាពនៃការប្តឹងដែលគ្មានទីបញ្ចប់[27]។

15. ដោយអនុម័តយកការសង្កេតរបស់អង្គបុរេជំនុំជម្រះ ដែលបានលើកឡើងរួចហើយនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចំពោះបណ្តឹងឧទ្ធរណ៍ PTC07[28] អង្គបុរេជំនុំជម្រះសម្រេចបដិសេធបណ្តឹងឧទ្ធរណ៍នេះ ដោយមិនពិចារណាពីភាពអាចទទួលយកបានរបស់បណ្តឹងឧទ្ធរណ៍ តាមវិធាន ៧៣, ៧៤ និង ២១ នៃវិធានផ្ទៃក្នុង ហើយក៏មិនពិចារណាលើអង្គសេចក្តីរបស់បណ្តឹងឧទ្ធរណ៍ដែរ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

បដិសេធបណ្តឹងឧទ្ធរណ៍នេះ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Rowan DOWNING** **ន័យ ផុល** **Chang-ho CHUNG** **ហួត វុទ្ធី**

---

[27] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D190/1/2 កថាខណ្ឌ ២០។

[28] ដូចជើងទំព័រខាងលើ

*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់* [redacted] *ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធពាក្យសុំមោឃភាព*